# អ្នកបោះឆ្នោតថ្មី

**VOTE 2016**

*ជាអ្នកបោះឆ្នោតថ្មី? សូមកុំបារម្ភ ដំណាក់កាលទាំង នេះបង្ហាញអំពីដំណើរការបោះឆ្នោត។*

## *ទៅស្ថានីយបោះឆ្នោតរបស់អ្នក*

អ្នកត្រូវទៅបោះឆ្នោតនៅកន្លែងបោះឆ្នោតរបស់អ្នកដែលបានកំណត់។ ជាទូទៅកន្លែងបោះឆ្នោតត្រូវនៅក្បែរ កន្លែងដែលអ្នករស់នៅ។ សូមស្វែងរកកន្លែងបោះឆ្នោត របស់អ្នកតាមរយៈវេបសាយត៍ mnvotes.org។ ការិយាល័យបោះឆ្នោតភាគច្រើនបើកចាប់ពីម៉ោង7ព្រឹក រហូតដល់ម៉ោង8យប់។

## *ចុះឈ្មោះ ឬចុះបញ្ជី*

ប្រសិនបើអ្នកបានចុះក្នុងបញ្ជីបោះឆ្នោត ឈ្មោះរបស់អ្នកនឹងមាននៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត។ ប្រសិនបើអ្នកបានចុះក្នុងបញ្ជី អ្នកពុំចាំបាច់បង្ហាញឯកសារអត្តសញ្ញាណនៅពេលចុះឈ្មោះឡើយ។

ប្រសិនបើអ្នកមិនបានចុះក្នុងបញ្ជីបោះឆ្នោតមុនថ្ងៃបោះឆ្នោតទេ អ្នកត្រូវបង្ហាញភ័ស្តុតាងអំពីអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក។ ឧទាហរណ៍ អ្នកអាចបង្ហាញប័ណ្ណបើកបរ Minnesota បច្ចុប្បន្នរបស់អ្នក ឬឯកសារបញ្ជាក់អត្តសញ្ញាណរដ្ឋ។ ឬអ្នកអាចបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណមានរូបថតដែលមានអាសយដ្ឋានចាស់របស់អ្នក រួមជាមួយប័ណ្ណបង្ហាញអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកផងដែរ។

សម្រាប់បញ្ជីឯកសារបញ្ជាក់អត្តសញ្ញាណ និងឯកសារគ្រប់ប្រភេទដែលអ្នកអាចយកមកជាមួយ សូមបើកមើលវេបសាយត៍ mnvotes.org។

### *កាលបរិច្ឆេទឆ្នាំ 2016*

***ការបោះឆ្នោតបឋម***
*ថ្ងៃអង្គារ៍ទី09 ខែសីហា*

***ការបោះឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន***
*បោះឆ្នោតតាមសំបុត្រ ឬដោយផ្ទាល់ថ្ងៃទី23 ខែកញ្ញា រហូតដល់ថ្ងៃទី7 ខែវិច្ឆិកា*

***ចុះឈ្មោះបោះឆ្នោត***
*ចុះឈ្មោះជាមុននៅត្រឹមថ្ងៃទី18 ខែតុលា ដើម្បីសន្សំសំចៃពេលវេលានៅថ្ងៃបោះឆ្នោត។*

***ថ្ងៃបោះឆ្នោត***
*ថ្ងៃអង្គារ៍ទី8 ខែវិច្ឆិកា*

*តទៅទំព័រក្រោយ...*

# អ្នកបោះឆ្នោតថ្មី

VOTE 2016

*.... តពីទំព័រមុខ*

## *ការបោះឆ្នោត*

អ្នកនឹងបោះឆ្នោតនៅកន្លែងដាច់ដោយឡែក ហើយ ការបោះឆ្នោតរបស់អ្នកមានលក្ខណៈសម្ងាត់។ បោះឆ្នោតដោយប្រើប៊ិច ឬខ្មៅដៃ និងគូសក្នុងរង្វង់រាង ពងក្រពើនៅជិតឈ្មោះបេក្ខជនដែលអ្នកជ្រើសរើស។

ការណែនាំនៅលើសន្លឹកឆ្នោតនឹងបង្ហាញថាតើបេក្ខជនចំនួនប៉ុន្មាននាក់ដែលអ្នកអាចជ្រើសរើសសម្រាប់ការិយាល័យនីមួយៗ។ ជាទូទៅគឺបង្ហាញថា "សូមជ្រើស រើសម្នាក់"។ ការិយាល័យក្នុងមូលដ្ឋានមួយចំនួនអាចមានអសនៈលើសពីមួយដើម្បីគូស។

សន្លឹកឆ្នោតរបស់អ្នកនឹងទុកជាបានការប្រសិនបើអ្នក មិនគូសលើគ្រប់ជម្រើស ឬសំណួរលើសន្លឹកឆ្នោត។

## *យកសន្លឹកឆ្នោតរបស់អ្នកទៅដាក់ ក្នុងប្រអប់សន្លឹកឆ្នោត*

បន្ទាប់ពីអ្នកបានគូសសន្លឹកឆ្នោត សូមដាក់សន្លឹកឆ្នោត របស់អ្នកទៅក្នុងម៉ាស៊ីនរាប់សន្លឹកឆ្នោត។ សូមប្រាកដ ថាអ្នកបានយកស្ទីគើរ "ខ្ញុំបានបោះឆ្នោត" របស់អ្នកមុនពេលដែលអ្នកចាកចេញ!

## *បោះឆ្នោតមុនពេលកំណត់ជាមួយនឹងសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន*

អ្នកអាចបោះឆ្នោតមុនពេលកំណត់នៅការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកដោយចាប់ផ្តើមពីថ្ងៃសុក្រទី23 ខែកញ្ញា។ អ្នកក៏អាចដាក់ពាក្យស្នើសុំឱ្យបញ្ជូន សន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានតាមលិខិតផងដែរ។ ដើម្បីស្វែងរកការិយាល័យបោះឆ្នោតក្នុងមូលដ្ឋាន របស់អ្នក ឬដើម្បីស្នើសុំសន្លឹកឆ្នោតសម្រាប់ពលរដ្ឋ អវត្តមាន សូមចូលទៅកាន់វេបសាយត៍ mnvotes.org។

### *ការឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោត*

*អ្នកមានសិទ្ធិក្នុងការឈប់សម្រាកពីការងារដើម្បីទៅ បោះឆ្នោតដោយគ្មានការកាត់ប្រាក់បៀវត្សរ៍ ការឈប់ សម្រាប់ផ្ទាល់ខ្លួន ឬពេលវេលាវិស្សមកាល។*